**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៥៧ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកំណត់សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ១០៦/អនក្រ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០១ ណែនាំការអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញភាពចាំបាច់នៃការងារគ្រប់គ្រង ។

## សំរេច

**ប្រការ ១ :** និយមន័យដែលបញ្ចូលជាបច្ចេកសព្ទនៃប្រកាសនេះ ហើយត្រូវបានហៅថាជា«បច្ចេកសព្ទនិយមន័យ» គឺជាផ្នែកមួយនៃប្រកាសនេះ ។ និយមន័យទាំងនេះគឺជាខ្លឹមសារនៃពាក្យ និងឃ្លា និងជាឯកសារ យោងដែលបានប្រើប្រាស់ ឬនឹងត្រូវបានប្រើប្រាស់នៅក្នុងប្រកាសនេះ ឬត្រូវប្រើប្រាស់ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកែប្រែ ឬរៀបចំបន្ថែមលើ តារាងនិយមន័យបច្ចេកសព្ទនេះបានគ្រប់ពេល ហើយត្រូវជូនដំណឹងនិងផ្តល់ការពិភាក្សាលើសំណើ ផ្លាស់ប្តូរប្រកបដោយហេតុផលសមស្រប ។

**ប្រការ ២ :** ពាក្យថា « ការធានារ៉ាប់រង » នៅក្នុងប្រកាសនេះគឺជាកិច្ចសន្យាធានារ៉ាប់រងមួយ ដែលអ្នកស្នើសុំ អោយមានការធានារ៉ាប់រង ដូចដែលបានចុះកិច្ចសន្យាបង់បុព្វលាភធានារ៉ាប់រងទៅអោយក្រុមហ៊ុន ធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងនេះត្រូវទទួលខុសត្រូវធានាសំណងចំពោះការបាត់បង់ និង ការខូចខាតទ្រព្យសម្បត្តិ ដែលបង្កដោយគ្រោះថ្នាក់ ឬនៅពេលដែលអ្នកទទួលការធានារ៉ាប់រង ទទួលរងគ្រោះដោយរបួសស្នាមលើរាងកាយ មានពិការភាព ឬមានជំងឺ ។

**ប្រការ ៣ :** ការធានារ៉ាប់រងលើអចលនទ្រព្យ សំដៅការធានារ៉ាប់រងលើការខាតបង់ទ្រព្យសម្បត្តិ និងខូចខាត អចលនទ្រព្យ ការទទួលខុសត្រូវលើអចលនទ្រព្យ ការសាងសង់ ការតំឡើង ការដឹកជញ្ជូនផ្លូវគោក ផ្លូវអាកាស និង ផ្លូវទឹក ការធ្វើដំណើរ ការធានារ៉ាប់រងលើតួនាវា ការធានារ៉ាប់រងលើយន្តហោះ និងឥណទានពាណិជ្ជកម្ម ព្រមទាំងគ្រោះថ្នាក់ចំពោះឯកត្តជន ។ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ អាចដំណើរការអាជីវកម្មធានារ៉ាប់រងបានតែក្នុងករណី នៃវិសាលភាពដែលមានចែងនៅក្នុងអាជ្ញា-ប័ណ្ណតែប៉ុណ្ណោះប្រសិនបើមាន និងដូចដែលបានឯកភាព ឬ ដោយបានបញ្ជាក់ដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុតែប៉ុណ្ណោះតាមពេលវេលាជាក់ស្តែង លើកលែងតែការធានារ៉ាប់រងលើ គ្រោះថ្នាក់ និងលើគ្រោះថ្នាក់ការងារ ដែលក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អាចដំណើរការកិច្ចប្រតិ-បត្តិការដូចគ្នា ។

**ប្រការ ៤ :** ប្រកាសនេះអនុវត្តចំពោះក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬ ក្រុមហ៊ុនធានារ៉ាប់រងមិនមែនជីវិត និងក្រុម-ហ៊ុនធានារ៉ាប់រងបន្ត ឬសាខានៃក្រុមហ៊ុនធានារ៉ាប់រងបរទេស និងក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេស ដែលបានទទួលសិទ្ធិស្របច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតអំពីកម្មសិទ្ធិភាព

ឡើយ ។ ការធ្វើអាជីវកម្មដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការមិនគោរពតាមច្បាប់ស្តីពី ការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង និងការមិនអនុវត្តតាមប្រកាសនេះ ព្រមទាំងសេចក្តីណែនាំ ឬកិច្ចព្រមព្រៀងពាក់ព័ន្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអំពើខុសច្បាប់ ។

**ប្រការ ៥ :** សេចក្តីណែនាំស្តីពី ទំរង់ និងខ្លឹមសារនៃ របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីណែនាំលើបញ្ហាបច្ចេកទេសផ្សេងៗ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចេញតាមការចាំបាច់ និងតាមពេលវេលាជាក់ស្តែង ។ ការមិនគោរពតាមប្រកាសនេះ ឬមិនគោរពច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង សេចក្តីណែនាំ ឬកិច្ចព្រមព្រៀងដទៃទៀត ដែលបានឯកភាពជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺអំពើខុសច្បាប់ ។

**<u>ការផ្តល់អាជ្ញាប័ណ្ណ</u>**

**ប្រការ ៦ :** មុនពេលចាប់ផ្តើមធ្វើអាជីវកម្មធានារ៉ាប់រង ក្រុមហ៊ុនដែលបានដាក់ពាក្យសុំអាជ្ញាប័ណ្ណធានារ៉ាប់រង ត្រូវបំពេញនូវលក្ខខណ្ឌរបស់ច្បាប់ អនុក្រឹត្យ និងច្បាប់ដទៃទៀត ព្រមទាំងលក្ខខណ្ឌបន្ថែម ឬសេចក្តីណែនាំដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមពេលវេលាជាក់ស្តែង ។

**ប្រការ ៧ :** ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ត្រូវដាក់ពាក្យមកកាន់ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលអាជ្ញាប័ណ្ណសំរាប់ដំណើរការអាជីវកម្មធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា ។ នៅពេលដាក់ពាក្យស្នើសុំ អ្នកស្នើសុំត្រូវផ្តល់ឯកសារទាំងឡាយដែលបញ្ជាក់ថា អ្នកស្នើសុំបានបំពេញតាមលក្ខខណ្ឌនៃសាធនភាពគ្រប់គ្រាន់ តាមការកំណត់នៅក្នុងប្រកាសនេះ ។

អាជ្ញាប័ណ្ណធានារ៉ាប់រងគឺមានសុពលភាពរយៈពេល ៥ ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើអាជ្ញាប័ណ្ណ ហើយអាចបន្តបានរយៈពេល ៣ ឆ្នាំម្តង ។ ការបន្តអាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណអោយបានយ៉ាងតិចណាស់ ៣ ខែ មុនពេលអាជ្ញាប័ណ្ណអស់សុពលភាព ។ ការបន្តអាជ្ញាប័ណ្ណគឺពឹងផ្អែកលើការគោរពទៅតាមលក្ខខណ្ឌដូចដែលបានចែងនៅក្នុងច្បាប់ អនុក្រឹត្យ

ប្រកាស សារាចរណែនាំ ឬការតម្រូវផ្សេងៗ ឬការណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជារៀងរាល់ពេល ។

## សាធនភាព

**ប្រការ ៨ :** ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវមានប្រាក់គ្រប់គ្រាន់សំរាប់សាធនភាព ។ ចំពោះអាជីវកម្មធានារ៉ាប់រងទូទៅ ប្រាក់សាធនភាពមិនត្រូវតិចជាងទឹកប្រាក់អតិបរិមានៃ ÷

ក. ១.៥០០.០០០ ដុល្លារអាមេរិក (មួយលានប្រាំរយពាន់) ។ ចំនួនប្រាក់សាធនភាពនេះ រួមបញ្ចូលទាំងប្រាក់តំកល់នៅធនាគារជាតិនៃកម្ពុជាចំនួន ៧០០.០០០ ដុល្លារអាមេរិក (ប្រាំពីររយពាន់) ដែលអាចជាសាច់ប្រាក់សុទ្ធ ឬជាមូលប័ត្ររដ្ឋដែលមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ

ខ. ៣០%នៃចំណូលបុព្វលាភសុទ្ធនៅរបាយការណ៍ហិរញ្ញវត្ថុសំរាប់ឆ្នាំចុងក្រោយ ។

កំរិតប្រាក់សាធនភាពនេះ ត្រូវជ្រើសរើសយកស្ថានភាពណាដែលខ្ពស់ជាងក្នុងចំណោម «ក» និង «ខ»។

គ. ជារៀងរាល់ពេល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងកំណត់មូលដ្ឋាននៃការគណនាសាធនភាពចំពោះក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបន្ត និងបរិមាណទ្រព្យសកម្ម ប្រភេទនៃទ្រព្យសកម្ម និងទីកន្លែងរបស់ទ្រព្យសកម្ម ដែលគាំទ្រសាធនភាព និងប្រាក់បំរុងបច្ចេកទេស ។ ប្រាក់បំរុងបច្ចេកទេសមានន័យថា បរិមាណទឹកប្រាក់ដែលបានមកពីការប្រើប្រាស់វិធីសាស្ត្រវាយតំលៃ ដែលអាចទទួលយកបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះសំណងទាមទារមិនទាន់ទូទាត់ និងបុព្វលាភមិនទាន់ចាត់ជាចំណូលសុទ្ធនៃការធានារ៉ាប់រងបន្ត (រួមមានសមាមាត្រ និងមិនមែនសមាមាត្រ)។

ឃ. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងជូនដំណឹងអោយបានគ្រប់គ្រាន់អំពីសំណើផ្លាស់ប្តូរណាមួយ និងបញ្ជាក់ពីកាលបរិច្ឆេទក្នុងការអនុវត្តន៍ ។

ង. តាមរយៈសេចក្តីណែនាំ និងសេចក្តីជូនដំណឹង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបញ្ជាក់នូវទុនសាធនភាពដែលតំរូវអោយមានសំរាប់ក្រុមហ៊ុនណាមួយ ដោយមិនតិចជាងចំនួនដែលបានចែងខាងលើឡើយ ។

ច. ដំណើរការអាជីវកម្មដោយពុំមានប្រាក់សាធនភាពគ្រប់គ្រាន់តាមការកំណត់ ហើយការមិនគោរពតាមប្រកាសនេះ ឬមិនគោរពច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង ក៏ដូចជាសេចក្តីសំរេច ឬកិច្ចព្រមព្រៀងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺអំពើខុសច្បាប់ ។

ប្រការ ៩ : ទាក់ទងនឹងប្រាក់ចំណេញរបស់ក្រុមហ៊ុនធានារ៉ាប់រងមួយ មិនត្រូវបានអនុញ្ញាតអោយបែងចែកភាគលាភទៅកាន់ភាគទុនិករបស់ខ្លួនឡើយ លុះត្រាតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយល់ព្រមជាលាយល័ក្ខអក្សរថាក្រុមហ៊ុនបានឆ្លើយតប ហើយអាចបន្តឆ្លើយតបនឹងកាតព្វកិច្ចសាធនភាពនៅក្នុងពេលខាងមុខដ៏ខ្លី ។ ការបើកប្រាក់ភាគលាភ ឬចំណូលទុនអាចដំណើរការទៅបានប្រសិនបើមានការឯកភាពជាលាយល័ក្ខអក្សរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុណ្ណោះ ។

## ការធានារ៉ាប់រងបន្ត

ប្រការ ១០ : ការរៀបចំក្នុងការធានារ៉ាប់រងបន្តចេញទៅក្រៅប្រទេសទាំងអស់ ចាំបាច់ត្រូវតែដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រចាំឆ្នាំ ។ ក្នុងរវាង ៣ ខែដើមឆ្នាំ ដែលការរៀបចំចាត់ចែងទាំងនោះត្រូវអនុវត្ត និងត្រូវផ្លាស់ប្តូរ កាត់បន្ថយឬបង្កើនឡើង ទៅតាមការណែនាំរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ របាយការណ៍ពាក់ព័ន្ធនឹងការធានារ៉ាប់រងបន្តទៅក្រៅដែលបានធ្វើសវនកម្មហើយ ត្រូវធ្វើអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរវាង ៣ ខែដើមឆ្នាំនីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចណែនាំអោយធ្វើរបាយការណ៍តាមគំរូដែលបានតំរូវ ។

ប្រការ ១១ : ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬ ក្រុមហ៊ុនធានារ៉ាប់រងមិនមែនអាយុជីវិតទាំងអស់ ត្រូវធានារ៉ាប់រងបន្តរហូតដល់ម្ភៃភាគរយ (២០%) នៃសេវាធានារ៉ាប់រងដែលបានចុះកិច្ចសន្យា (ចំនួនអតិបរមា និងត្រូវបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនដែលទទួលយក និង ក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋ) ជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋ ។

## ទ្រព្យសកម្ម

ប្រការ ១២ : ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណ ដើម្បីប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវប្រើប្រាស់មូលធនបច្ចុប្បន្នរបស់ខ្លួន និងមូលនិធិបំរុងបច្ចេកទេសរបស់ខ្លួននៅក្នុងទ្រព្យសកម្ម ដូចដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំណត់តាមពេលវេលាជាក់ស្តែង ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកំណត់នូវបរិមាណ និងសមាមាត្រនៃមូលធនបច្ចុប្បន្នដែលមានទៅក្នុងទ្រព្យសកម្មណាមួយ ។

## ការដោះស្រាយបណ្តឹងទាមទារសំណង

**ប្រការ ១៣** : វិធីសាស្ត្រនៃការដោះស្រាយបណ្តឹងទាមទារសំណង ជាដំបូងត្រូវមានមូលដ្ឋានផ្អែកទៅលើការចរចារដោយសន្តិវិធី និងសម្រុះសម្រួលរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកទទួលការធានារ៉ាប់រង ឬតតិយភាគីដែលជាភាគីរងគ្រោះ ។ ប្រសិនបើការសម្រុះសម្រួលមិនទទួលជោគជ័យ ពាក្យបណ្តឹងនេះនឹងត្រូវបញ្ជូនទៅអោយមជ្ឈត្តករសំរាប់ធ្វើការដោះស្រាយ ។ ដើម្បីចាត់ការនៅក្នុងការដោះស្រាយសំណង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានកិច្ចព្រមព្រៀងពីអ្នកទទួលការធានារ៉ាប់រង និងពីក្រុមហ៊ុនធានារ៉ាប់រង អាចតែងតាំងមជ្ឈត្តករ ឬបង្កើតគណៈកម្មការមជ្ឈត្តករសំរាប់កំណត់វិវាទ ។ នៅក្នុងករណីដែលភាគីទាំងពីរនៅមិនទាន់ឯកភាពគ្នា ភាគីដែលមិនយល់ព្រមអាចនឹងប្តឹងទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

## នាយកគណៈកម្មាធិការប្រតិបត្តិ និង ក្រុមប្រឹក្សា

**ប្រការ ១៤** : នៅក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងមួយមានបំណងចង់ផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយករបស់ខ្លួន ក្រុមហ៊ុននោះត្រូវរាយការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យទៅលើលក្ខណៈសម្បត្តិចំពោះបុគ្គលដែលត្រូវមកកាន់មុខតំណែងនេះ ។ ប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយកណាក៏ដោយចាំបាច់ត្រូវមានបទពិសោធន៍ និងជំនាញសមស្របហើយត្រូវបំពេញលក្ខណៈវិនិច្ឆ័យ «សមស្រប» ដូចដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមពេលវេលាជាក់ស្តែង ហើយបុគ្គលនោះត្រូវតែទទួលការឯកភាពពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិនមុននឹងធ្វើការតែងតាំង ។

**ប្រការ ១៥** : ប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយក នាយក និងប្រធានគណៈកម្មាធិការប្រតិបត្តិ ឬបេក្ខភាពប្រធានក្រុមប្រឹក្សាភិបាល បេក្ខភាពនាយក បេក្ខភាពអគ្គនាយក ឬបេក្ខភាពប្រធានគណៈកម្មាធិការប្រតិបត្តិចាំបាច់ត្រូវមានបទពិសោធន៍ និងជំនាញព្រមទាំងបំពេញនូវលក្ខណៈវិនិច្ឆ័យ «សមស្រប» ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមពេលវេលាជាក់ស្តែង ។ បេក្ខជនសំរាប់ធ្វើការតែងតាំង ចាំបាច់ត្រូវតែទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិនមុននឹងធ្វើការតែងតាំង ។

**ប្រការ ១៦** : បុគ្គលដែលកាន់មុខតំណែងជា នាយក ប្រធាននាយកប្រតិបត្តិ ឬ នាយកចាត់ការ ត្រូវតែជា «បុគ្គលល្អ និងត្រឹមត្រូវ» ហើយមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

ក. មានភាពសុចរិតទៀងត្រង់ មានសមត្ថភាព និងលក្ខណៈវិនិច្ឆ័យសមស្របសំរាប់បំពេញនូវភារកិច្ច នៃមុខតំណែងនោះ ។

ខ. បំពេញការងារដោយយកចិត្តទុកដាក់ និងមានភាពទទួលខុសត្រូវខ្ពស់ និងបំពេញលក្ខណៈវិនិច្ឆ័យផ្សេងទៀត ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ១៧** : បុគ្គលដែលត្រូវទទួលតំណែងជាប្រធាននាយកប្រតិបត្តិ ឬ នាយកចាត់ការត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

ក. ត្រូវមានកម្រិតវប្បធម៌ខ្ពស់ និងមានបទពិសោធន៍ ដែលអាចអនុញ្ញាតអោយសាមីខ្លួនបំពេញតួនាទីបានសមស្របនូវភារកិច្ចរបស់ខ្លួន ។

ខ. មិនត្រូវមានមុខតំណែងនៃការទទួលខុសត្រូវក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ក្រុមហ៊ុនណាមួយដែលត្រូវបានចោទប្រកាន់អំពីបទល្មើសនៅក្រោមច្បាប់ណាមួយនៅក្នុងអំឡុងពេល ឬអាណត្តិការងាររបស់ខ្លួន លើកលែងតែមានបុគ្គលមានសមត្ថកិច្ចណាមួយបញ្ជាក់ថា ការរំលោភនោះបានប្រព្រឹត្តទៅដោយខ្លួនពុំបានដឹង ឬ ខ្លួនពុំបានឯកភាព ហើយសាមីជនពុំឋិតនៅក្នុងមុខតំណែងបង្កបទល្មើសនោះទេ ។

គ. មិនត្រូវមានមុខតំណែងនៃការទទួលខុសត្រូវ ក្នុងគណៈកម្មាធិការគ្រប់គ្រងនៃក្រុមហ៊ុនណាមួយដែលនៅក្នុងអំឡុងអាណត្តិធ្វើការងាររបស់ខ្លួន÷

១. មិនបានទូទាត់ប្រាក់ពិន័យតាមការទាមទារ ។

២. បានពន្យាពេលការទូទាត់ ឬ បានបង្កើននូវប្រាក់ជំពាក់ឥណទាយករបស់ខ្លួន ឬ

៣. ធ្លាប់មានគេតែងតាំងនាយកគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ ។

ឃ. ត្រូវមានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើការងារពេញម៉ោង ហើយមិនអាចធ្វើអាជីវកម្មណាផេទៀត ឬបំពេញមុខវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា លើកលែងតែធ្វើជានាយកពុំមែនប្រតិបត្តិ ឬជាភាគទុនិករបស់ក្រុមហ៊ុនមួយទៀត ។

ង. មិនត្រូវពាក់ព័ន្ធជាមួយនឹងសកម្មភាពនយោបាយឡើយ ។

ច. មិនត្រូវបង្កអោយមានទំនាស់ផលប្រយោជន៍ជាមួយនឹងក្រុមហ៊ុន ទោះបីជាតាមរយៈសាមីខ្លួនឯង ឬតាមរយៈប្តីប្រពន្ធកូនឪពុកម្តាយ ឬបងប្អូនរបស់ខ្លួនឡើយ ។

ជ. មិនត្រូវធ្វើសកម្មភាពតាមបែបណាមួយ ដែលបង្កអោយមានមន្ទិលសង្ស័យទៅលើសមត្ថភាពរបស់ខ្លួន នៅក្នុងការកាន់មុខតំណែងជាប្រធាននាយកប្រតិបត្តិ ឬនាយកចាត់ការ ឬធ្វើសកម្មភាពយ៉ាងចំហរ ដោយផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈ ជាពិសេសក្នុងការចាត់ការជាមួយម្ចាស់ប័ណ្ណសន្យាធានារ៉ាប់រង អ្នកទាមទារសំណង និងជាមួយអតិថិជន ។

ឈ. មិនត្រូវជាភាគីមួយ ចំពោះសកម្មភាពណាមួយ ឬ សេចក្តីសំរេចណាមួយ នៃគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនដែលប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ក្រុមហ៊ុនធានារ៉ាប់រង ដែលបានទទួលអាជ្ញាប័ណ្ណ និងម្ចាស់ប័ណ្ណសន្យាធានារ៉ាប់រងរបស់ខ្លួន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិពេញលេញក្នុងការកំណត់ថាតើបុគ្គលណាម្នាក់បានអនុវត្តតាមលក្ខខណ្ឌវិនិច្ឆ័យនេះ ។

## ភាគព្វកិច្ចផ្នែកហិរញ្ញវត្ថុ និង ស្ថិតិ

**ប្រការ ១៨** : នៅក្នុងរយៈពេលប្រាំមួយ (៦)ខែ ដោយគិតចាប់ពីចុងការិយបរិច្ឆេទនីមួយៗ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបន្តត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ក៏ដូចជាឯកសារចាំបាច់ដទៃទៀតរបស់ក្រុមហ៊ុនដែលទើបបានបញ្ចប់ទៅថ្មីៗរួមមានឯកសារទាំងឡាយណា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតំរូវអោយ ។

**ប្រការ ១៩** : ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវរៀបចំស្ថិតិអាជីវកម្ម និ ងខ្លឹមសារសង្ខេបប្រចាំខែ ហើយផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមានពត៌មានដែលមានចែងនៅក្នុងច្បាប់ ព្រមទាំងពត៌មានដទៃទៀតដែលតំរូវដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចដែលបានចែងនៅក្នុងអាទិភាពដែលបានយល់ព្រមក្នុងគំរូរបាយការណ៍ ។

**ប្រការ ២០** : របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានអាជ្ញា-ប័ណ្ណត្រូវបានគេបង្កើតឡើងដោយប្រើប្រាស់នូវស្តង់ដារគណនេយ្យទូទៅ ដែលបានទទួលស្គាល់ដោយកម្ពុជា ដូចដែលបានចែងនៅក្នុងប្រកាស ឬកែប្រែដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមពេលវេលាជាក់ស្តែង ឬបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ២១** : របាយការណ៍ហិរញ្ញវត្ថុរបស់អ្នកធានារ៉ាប់រង និងអ្នកធានារ៉ាប់រងបន្តដែលមានអាជ្ញាប័ណ្ណត្រូវកែសំរួលនូវមូលនិធិ ចំពោះអ្នកមានភាគហ៊ុនដើម្បីកំណត់សាធនភាព ដោយប្រើប្រាស់វិធីសាស្ត្រដែលអាចទទួលយកបានសំរាប់ការគណនាបុព្វលាភដែលមិនទាន់ទទួលបាន (ឬហានិភ័យដែលមិនទាន់ហួសកំណត់) និងការទាមទារអោយសងប្រាក់ធានារ៉ាប់រងដូចដែលបានចែងនៅក្នុងតំរោងនិយមន័យ ។

**ប្រការ ២២** : របាយការណ៍ហិរញ្ញវត្ថុត្រូវកែសំរួលតាមមូលនិធិអ្នកមានភាគហ៊ុនដើម្បីកំណត់សាធនភាព ដោយធ្វើការវាយតំលៃទ្រព្យសកម្ម ឬដកទ្រព្យសកម្មចេញដូចដែលបានចែងនៅក្នុងតំរោងនៃគំរូគណនេយ្យ ដោយយោងតាមទ្រព្យសកម្ម និងដោយពឹងផ្អែកលើការផ្លាស់ប្តូរ ឬកែប្រែជាប្រចាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់អ្នកធានារ៉ាប់រងទាំងអស់ ឬអ្នកធានារ៉ាប់រងជាពិសេស ។

**ប្រការ ២៣** : បទប្បញ្ញត្តិទាំងអស់ដែលមានទំនាស់ទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ២៤** : ប្រកាសនេះមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

កន្លែងទទួល

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ឯកសារ- កាលប្បវត្តិ